ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងឃុំបឹងល្វា ជាមួយឃុំកំពង់ថ្ម និងឃុំប្រាសាទ នៃស្រុកសន្ទុក ខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងឃុំបឹងល្វា ជាមួយឃុំកំពង់ថ្ម និងឃុំប្រាសាទ នៃស្រុកសន្ទុក ខេត្តកំពង់ធំ ដោយកាត់យកភូមិចំនួន០៤ ពីឃុំបឹងល្វា គឺភូមិត្រពាំងទឹម ភូមិកោះបង្កៅ ភូមិត្រពាំងប្រី និងភូមិបឹងល្វា មកឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ឃុំកំពង់ថ្ម និងកាត់យកភូមិចំនួន០២ ពីឃុំបឹងល្វា គឺភូមិត្បែង និងភូមិសង្គ្រោះ មកឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ឃុំប្រាសាទ។

ផ្អែកតាមការកែសម្រួលនេះ ព្រំប្រទល់រដ្ឋបាលរវាងឃុំបឹងល្វា ជាមួយឃុំកំពង់ថ្ម និងឃុំប្រាសាទ នៃស្រុកសន្ទុក ខេត្តកំពង់ធំ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងឃុំបឹងល្វា ជាមួយឃុំកំពង់ថ្ម និងឃុំប្រាសាទ នៃស្រុកសន្ទុក ខេត្តកំពង់ធំ ត្រូវចូលជាធរមានសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី៥ ស្របតាមខ្លឹមសារមាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្តកំពង់ធំ គណៈអភិបាលខេត្តកំពង់ធំ ក្រុមប្រឹក្សាស្រុកសន្ទុក គណៈអភិបាលស្រុកសន្ទុក ក្រុមប្រឹក្សាឃុំបឹងល្វា ក្រុមប្រឹក្សាឃុំកំពង់ថ្ម និងក្រុមប្រឹក្សាឃុំប្រាសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ផែនទីកែសម្រួលព្រំប្រទល់រដ្ឋបាល រវាងឃុំបឹងល្វា ជាមួយឃុំប្រាសាទ និងឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ
ដោយកាត់ផ្ទៃដីទំហំ ៨១៧ ហិកតា ពីឃុំបឹងល្វា ក្នុងនោះ ឱ្យទៅឃុំប្រាសាទទំហំ២២៨ ហិកតា និងឱ្យទៅឃុំកំពង់ថ្មទំហំ៥៨៩ ហិកតា
ផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ............១៤៤......អនក្រ.បក
ធ្វើនៅថ្ងៃទី..២០....ខែ.សីហា....ឆ្នាំ២០២១
រដ្ឋបាលខេត្តកំពង់ធំ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី
និយាមកាកាត់ឱ្យឃុំកំពង់ថ្ម
FID X Y
0 515585 1388778
1 516449 1388789
2 516453 1388324
3 516982 1388335
4 517416 1387192
5 516347 1386080
6 514569 1386070
7 514573 1387749
និយាមកាកាត់ឱ្យឃុំប្រាសាទ
FID X Y
0 515584 1391560
1 515688 1391349
2 515944 1391413
3 516073 1391485
4 516239 1391342
5 518395 1391363
6 518460 1391157
7 518449 1388789
8 515585 1388778
មាត្រដ្ឋាន: ១:៨៥,០០០
ប្រព័ន្ធកូអរដោនេ
ចំណោលផែនទី: WGS_1984_UTM_Zone_48N
សញ្ញាផែនទី
សាលាឃុំ
និយាមកាដីឃុំបឹងល្វាកាត់ឱ្យឃុំកំពង់ថ្ម
និយាមកាដីឃុំបឹងល្វាកាត់ឱ្យឃុំប្រាសាទ
ភូមិ
ផ្លូវរលំជនបទ
ផ្លូវជាតិលេខ៦
ដីឃុំបឹងល្វាទំហំ៥៨៩ហិកតាកាត់ឱ្យឃុំកំពង់ថ្ម
ដីឃុំបឹងល្វាទំហំ២២៨ហិកតាកាត់ឱ្យឃុំប្រាសាទ
ឃុំកំពង់ថ្ម
ឃុំប្រាសាទ
ផែនទីស្រុកសន្ទុក
ផែនទីខេត្តកំពង់ធំ
បានឃើញ និង ឯកភាព
បានឃើញ និង យល់ព្រម
បានឃើញ និង ពិនិត្យត្រឹមត្រូវ
គូរ និងរៀបចំដោយ
សម្ដេចក្រឡាហោម ស ខេង